ក្រសួងសុខាភិបាល
Ministry of Health
នាយកដ្ឋានប្រយុទ្ធនឹងជំងឺឆ្លង
Communicable Disease Control Department

Notice
Can't identify browser version. Agent: Mozilla/5.0 (Macintosh; Intel Mac OS X) AppleWebKit/534.34 (KHTML, like Gecko) Qt/4.8.7 Safari/534.34

# បច្ចុប្បន្នភាពនៃជំងឺកូរូណាថ្មី COVID-19 នៅប្រទេសកម្ពុជា

**សំរាប់ព័ត៌មានលំអិត សូមចុចមកលេខ 115**

**NEW COVID-19 Updated 30-03-2020**

រហូតម៉ោង ៩:២០នាទីព្រឹក ថ្ងៃទី ៣០ មីនា ២០២០ យើងរកឃើញអ្នកជំងឺ COVID-19 ៤នាក់ទៀត សរុបទាំងអស់ប្រទេសយើងមានចំនួន ១០៧ ករណី ហើយយើងបានព្យាបាល ជាសះស្បើយចំនួន ២នាក់ទៀត សរុប ២៣នាក់ ស្លាប់គ្មាន ។ យើងពុំទាន់រកឃើញភស្តុតាង បញ្ជាក់ថាមានការឆ្លងក្នុងសហគមន៍នៅឡើយទេ តែលទ្ធភាពនឹងអាចកើតមានឡើង ។
សូមបញ្ជាក់: ករណីជនជាតិអង់គ្លេស ពីរនាក់ព្យាបាលជាសះស្បើយ នៅមន្ទីរពេទ្យខ្មែរសូវៀត គាត់ទាំងពីរនាក់រកឃើញវិជ្ជមាននៅមន្ទីរពេទ្យខេត្តកំពង់ចាម តែត្រូវបានបញ្ជូនមកព្យាបាលនៅភ្នំពេញ ។
ពត៌មានបន្ថែមសូមទាក់ទងលេខ ១១៥

http://covid19-map.cdcmoh.gov.kh




---

រហូតម៉ោង ៨:២០នាទីព្រឹក ថ្ងៃទី ២៩ មីនា ២០២០ យើងរកឃើញអ្នកជំងឺ COVID-19 ១នាក់ទៀត (ភេទស្រីជនជាតិខ្មែរ ដែលបានប៉ះពាល់ផ្ទាល់ ជាមួយអ្នកជំងឺវិជ្ជមាន COVID-19) សរុបទាំងអស់ប្រទេសយើងមានចំនួន ១០៣ ករណី និង យើងបានព្យាបាលជា សះស្បើយចំនួន ៨នាក់ទៀត សរុប ២១នាក់ ស្លាប់គ្មាន ។
យើងពុំទាន់រកឃើញភស្តុតាង បញ្ជាក់ថាមានការឆ្លង ក្នុងសហគមន៍នៅឡើយទេ តែលទ្ធភាពនឹងអាចកើតមានឡើង ។
សូមបញ្ជាក់: ករណីជនជាតិអង់គ្លេសពីរនាក់ ព្យាបាលជាសះស្បើយនៅមន្ទីរខ្មែរ សូវៀត គាត់ទាំងពីរនាក់រកឃើញវិជ្ជមាន នៅមន្ទីរពេទ្យខេត្តកំពង់ចាម តែត្រូវបានបញ្ជូនមកព្យាបាលនៅភ្នំពេញ ។

ពត៌មានបន្ថែមសូមទាក់ទងលេខ ១១៥
http://covid19-map.cdcmoh.gov.kh
អរគុណ inSTEDD




---

រហូតម៉ោង ០៧:០០ព្រឹក ថ្ងៃទី ២៨ មីនា ២០២០ យើងរកឃើញអ្នកជំងឺ COVID-19 ០៤នាក់ (ជនជាតិខ្មែរ) សរុបទាំងអស់ប្រទេសយើងមានចំនួន ១០២ករណី និង យើងបានព្យាបាលជាសះស្បើយ ចំនួ១៣នាក់ ស្លាប់គ្មាន។

នៅយប់ថ្ងៃទី២៧ មីនា យើងពុំបានរកឃើញករណីថ្មីទេ ហើយនេះជាលើកទីមួយហើយ ដែលយើងមិនបានរកឃើញករណីថ្មី ។ យើងពុំទាន់រកឃើញភស្តុតាង បញ្ជាក់ថាមានការឆ្លង ក្នុងសហគមន៍នៅឡើយទេ តែលទ្ធភាពនឹងអាចកើតមានឡើង ។

សូមចុចមើល link ខាងក្រោមសំរាប់ចំនួនករណីលំអិត។ ពត៌មានបន្ថែមសូមទាក់ទងលេខ ១១៥
http://covid19-map.cdcmoh.gov.kh




---

រហូតម៉ោង ១០យប់ ថ្ងៃទី ២៦ មីនា ២០២០ យើងរកឃើញអ្នកជំងឺ COVID-19 ២នាក់ (ជនជាតិឥណ្ឌូនេស៊ីទាំងពីរ) សរុបទាំងអស់ប្រទេសយើងមានចំនួន ៩៨ករណី និង យើងបានព្យាបាលជាសះស្បើយ ចំនួ១នាក់ទៀត ស្លាប់គ្មាន សូមអានតារាងខាងក្រោម។ យើងពុំទាន់រកឃើញភស្តុតាង បញ្ជាក់ថាមានការឆ្លង

ក្នុងសហគមន៍នៅឡើយទេ តែលទ្ធភាពនឹងអាចកើតមានឡើង ។
ព័ត៌មានបន្ថែមសូមទាក់ទងលេខ ១១៥
**http://covid19-map.cdcmoh.gov.kh**
អរគុណ inSTEDD




---

រហូតម៉ោង ១៩ៈ៣០ នាទីយប់ ថ្ងៃទី ២៥ មីនា ២០២០ រកឃើញករណីថ្មីអ្នកវិជ្ជមាន COVID-19 ០២នាក់ ជាអ្នកទេសចរជនជាតិបារាំង និង ០៣នាក់ទៀត ជាជនជាតិខ្មែរ ហើយអ្នកជាសះស្បើយមានចំនួន ០៤នាក់។

សរុបអ្នកឆ្លងទាំងអស់ ៩៦នាក់ ក្នុងនោះ ១០ នាក់បានជាសះស្បើយ។

សំរាប់ទូរលេខលំអិតៈ https://covid19-map.cdcmoh.gov.kh/



---

រហូតម៉ោង ១១យប់ ថ្ងៃទី ២៤ មីនា ២០២០ យើងរកឃើញអ្នកជំងឺ COVID-19 ៤នាក់ (អង់គ្លេស២ អាមេរិក២) សរុបទាំងអស់ប្រទេសយើងមានចំនួន ៩១ករណី និង យើងបានព្យាបាលជាសះស្បើយ ចំនួន៦នាក់ ស្លាប់គ្មាន សូមអានតារាងខាងក្រោម។ យើងពុំទាន់រកឃើញភ័ស្តុតាង បញ្ជាក់ថាមានការឆ្លងក្នុងសហគមន៍ នៅឡើយទេ តែលទ្ធភាពនឹងអាចកើតមានឡើង ។
ព័ត៌មានបន្ថែមសូមទាក់ទងលេខ ១១៥
https://covid19-map.cdcmoh.gov.kh
អរគុណ inSTEDD





---

រហូតម៉ោង ១០យប់ ថ្ងៃទី ២៣ មីនា ២០២០ យើងរកឃើញអ្នកជំងឺ COVID-19 សរុបទាំងអស់ចំនួន ៨៧ករណី (ពេលព្រឹក២ករណី និងយប់១ករណី)
សូមអានតារាងខាងក្រោម ។ រហូតពេលនេះយើងបានព្យាបាលជាពីរនាក់ហើយគឺជនជាតិចិន១នាក់ និងជនជាតិអង់គ្លេស១នាក់ ។
យើងពុំទាន់រកឃើញភ័ស្តុតាងបញ្ជាក់ថាមានការឆ្លងក្នុងសហគមន៍នៅឡើយទេ តែលទ្ធភាពនឹងអាចកើតមានឡើង ។
សូមមើលតារាងភ្ជាប់មកជាមួយនេះ :
ព័ត៌មានបន្ថែមសូមទាក់ទងលេខ ១១៥




---

ម៉ោង ១០ព្រឹក ថ្ងៃទី ២៣ មីនា ២០២០

យើងរកឃើញអ្នកជំងឺ COVID-19 សរុបទាំងអស់ចំនួន ៨៦ករណី សូមអានតារាងខាងក្រោម។ រហូតពេលនេះ យើងបានព្យាបាលជាពីរនាក់ហើយ គឺជនជាតិចិន១នាក់ និងជនជាតិអង់គ្លេស១នាក់ ។ យើងពុំទាន់រកឃើញភ័ស្តុតាង បញ្ជាក់ថាមានការឆ្លង ក្នុងសហគមន៍នៅឡើយទេ តែលទ្ធភាពនឹងអាចកើតមានឡើង ។ សូមមើលតារាងភ្ជាប់មកជាមួយនេះ :
ព័ត៌មានបន្ថែមសូមទាក់ទងលេខ ១១៥



---

ម៉ោង ២២ៈ00 ថ្ងៃទី ២២ ខែ មីនា ឆ្នាំ២០២០

រកឃើញ ២៩ករណីថ្មីទៀត ជាអ្នកទេសចរជនជាតិបារាំង និងជនជាតិខ្មែរ ២នាក់ វិជ្ជមានវីរុសកូវីត១៩ នៅខេត្តព្រះសីហនុ ដែលធ្វើអោយចំនួន សរុប អ្នកមានវិជ្ជមានវីរុសកូវីត១៩ នៅកម្ពុជាកើនដល់ ៨៤នាក់



---

ម៉ោង ២០ៈ00 ថ្ងៃទី ២១ ខែមីនា ឆ្នាំ ២០២០

- រកឃើញ ២ករណីថ្មីទៀត ជាបុរសទេសចរជនជាតិបារាំង វិជ្ជមានវីរុសកូវីត១៩ ធ្វើឱ្យចំនួនអ្នកឆ្លងសរុបនៅក្នុងប្រទេសកម្ពុជា កើនដល់៥៣នាក់។

- ចំណែកស្ត្រីជនជាតិអង់គ្លេស (ពិការ) វ័យ ៦៥ឆ្នាំ អវិជ្ជមានវីរុសកូវីត១៩ ចំនួន២លើក




ម៉ោង ១៩:៣០ ថ្ងៃទី ២០ ខែ មីនា ឆ្នាំ ២០២០

រកឃើញ ៤ ករណីថ្មីទៀត មានវិជ្ជមានវីរុសកូវីត១៩

៣ករណី ជាបុរសជនជាតិខ្មែរ ដែរបានវិលត្រលប់ពីចូលរួមពិធីសាសនា នៅប្រទេសម៉ាឡេស៊ី និង ១ករណីទៀត ជាជនជាតិម៉ាឡេស៊ី ដូច្នេះសរុបទាំងអស់ចំនួន ៥១ករណី។

សូមមើលតារាងភ្ជាប់មកជាមួយនេះ :
ពត៌មានបន្ថែមសូមទាក់ទងលេខ ១១៥

   

---

រហូតម៉ោង ១០:៣០យប់ ថ្ងៃទី ១៩ មីនា ២០២០ យើងរកឃើញអ្នកជំងឺ COVID-19 ១០ករណីបន្ថែមទៀត ដូច្នេះសរុបទាំងអស់ចំនួន ៤៧ករណី, ៤៣ករណី នាំចូលពីប្រទេសក្រៅ ១ករណីប៉ះពាល់ផ្ទាល់ ជាមួយអ្នកជំងឺជនជាតិជប៉ុន និង២ករណី ជាប្រពន្ធពីរនាក់
ប៉ះពាល់ផ្ទាល់ជាមួយប្តីពីរនាក់មកពីបុណ្យសាសនាពីប្រទេសម៉ាឡេស៊ី ដែលរកឃើញមានផ្ទុកវិជ្ជមាន COVID-19។

យើងពុំទាន់រកឃើញភ័ស្តុតាង បញ្ជាក់ថាមានការឆ្លង ក្នុងសហគមន៏នៅឡើយទេ តែលទ្ធភាពនឹងអាចកើតមានឡើង ។
សូមមើលតារាងភ្ជាប់មកជាមួយនេះ :
ពត៌មានបន្ថែមសូមទាក់ទងលេខ ១១៥

 

---

ថ្ងៃទី ១៨ មីនា ២០២០ យើងរកឃើញអ្នកជំងឺ COVID19 សរុបទាំងអស់ចំនួន  ៣៧ករណី, ៣៦ករណីនាំចូលពីប្រទេសក្រៅ និង១ករណីប៉ះពាល់ផ្ទាល់ជាមួយអ្នកជំងឺជនជាតិជប៉ុន ។
យើងពុំទាន់រកឃើញភ័ស្តុតាងបញ្ជាក់ថាមានការឆ្លងក្នុងសហគមន៏នៅឡើយទេ តែលទ្ធភាពនឹងអាចកើតមានឡើង ។

    

ពត៌មានបន្ថែមសូមទាក់ទងលេខ ១១៥

---

រកឃើញ ៩ ករណីថ្មីទៀត មានវិជ្ជមានវីរុសកូវីត១៩ ធ្វើចំនួនសរុបកើនដល់ ៣៣ករណី។



---

រកឃើញ ១២ ករណីថ្មីទៀត មានវិជ្ជមានវីរុសកូវីត១៩

ក្នុងនោះ ១១ ករណីថ្មី ជាជនជាតិខ្មែរឥស្លាម ដែលវិលត្រលប់មកពីចូលរួម ពិធីសាសនា នៅប្រទេសម៉ាឡេស៊ី និងបុរសជនជាតិខ្មែរ ០១ នាក់ត្រលប់មកពីប្រទេសថៃ។



---

រហូតដល់ម៉ោង១១:២០នាទី យប់ ថ្ងៃទី១៥ មីនា ២០២០ យើងរកឃើញអ្នកជំងឺ COVID19 សរុបថ្ងៃនេះ ៥នាក់ទៀត (ពេលថ្ងៃប្រកាស១ករណី និងពេលយប់ប្រកាស៤ករណីទៀត) ដូច្នេះសរុបទាំងអស់ ១២ករណី ។

១១ករណីនាំចូលពីប្រទេសក្រៅ និង១ករណីប៉ះផ្ទាល់ជាមួយអ្នកជំងឺ ជនជាតិជប៉ុន ពួកគាត់ខ្លះមានសញ្ញាតិចតួច និងបុគ្គលផ្សេងទៀត គ្រាន់តែផ្ទុកមេរោគ COVID19 គ្មានរោគសញ្ញាគួឱ្យកត់សំគាល់ មានន័យថាមានសុខភាល្អនៅឡើយ ។
យើងពុំទាន់រកឃើញភ័ស្តុតាង បញ្ជាក់ថាមានការចំលងជំងឺ នៅក្នុងសហគមន៏ឡើយទេ ។

ពត៌មានបន្ថែមសូមទាក់ទងលេខ ១១៥



---

បច្ចុប្បន្នភាព ថ្ងៃទី ១៥ ខែ មីនា ឆ្នាំ២០២០

ក្រសួងសុខាភិបាល បានរកឃើញ Covid-19 ១ករណីទៀត លើខ្លួនជនជាតិបារាំង អាយុ៣៥ឆ្នាំ ដែលចូលមកប្រទេសកម្ពុជា ហើយឆ្លងកាត់សិង្ហបុរី បច្ចុប្បន្នកំពុងស្ថិតនៅ មន្ទីរពេទ្យរុស្ស៊ី រាជធានីភ្នំពេញ។

កម្ពុជាបានរកឃើញអ្នកកើតជំងឺ Covid-19 ចំនួន៨ករណីហើយ ក្នុងនោះមាន៖

ទី១៖ បុរសជនជាតិចិន មកពីទីក្រុងវូហាន (ជាសះស្បើយ)

ទី២៖ បុរសជនជាតិខ្មែរ វ័យ៣៨ឆ្នាំ នៅខេត្តសៀមរាប

ទី៣៖ ស្រ្តីជនជាតិអង់គ្លេស វ័យ៦៥ឆ្នាំ អ្នកដំណើរនាវា Viking Cruise Journey នៅខេត្តកំពង់ចាម

ទី៤៖ បុរសជនជាតិអង់គ្លេស វ័យ៧៣ឆ្នាំ អ្នកដំណើរនាវា Viking Cruise Journey នៅខេត្តកំពង់ចាម

ទី៥៖ ស្រីជនជាតិអង់គ្លេស វ័យ៦៩ឆ្នាំ អ្នកដំណើរនាវា Viking Cruise Journey នៅខេត្តកំពង់ចាម

ទី៦៖ បុរសជនជាតិកាណាដា អាយុ៤៩ឆ្នាំ នៅរាជធានីភ្នំពេញ

ទី៧៖ បុរសជនជាតិប៊ែលហ្សិក អាយុ៣៣ឆ្នាំ នៅរាជធានីភ្នំពេញ

ទី៨៖ បុរសជនជាតិបារាំង អាយុ៣៥ឆ្នាំ នៅរាជធានីភ្នំពេញ៕



---

បច្ចុប្បន្នភាព ម៉ោង ១៦:០០ ថ្ងៃទី ១៣ ខែ មីនា ឆ្នាំ២០២០

រកឃើញករណីវិជ្ជមានវីរុសកូវីត-១៩  ២ករណីទៀត នៅរាជធានីភ្នំពេញ។

យើងរកឃើញករណីជំងឺ COVID-19 សរុបចំនួន ៧ករណី
- ៦ករណី ជាជនបរទេស និង ១ករណី ជនជាតិខ្មែរ
- ១ករណី ជនជាតិចិន ភេទប្រុស អាយុ៦០ឆ្នាំ ជាសះស្បើយ
- ១ករណី ជនជាតិខ្មែរ ភេទប្រុស អាយុ៣៨ឆ្នាំ សុខភាពល្អ នៅសៀមរាប
- ៣ ករណី ជនជាតិអង់គ្លេស (ស្រី២ករណី ប្រុស១ករណី) ពួកគាត់គ្មានរោគសញ្ញាគួរឱ្យកត់សំគាល់ទេ និងមានសុខភាពល្អកំពុងព្យាបាលក្នុងមន្ទីរពេទ្យភ្នំពេញ
- ១ករណី ជនជាតិកាណាដា នៅភ្នំពេញ
- ១ករណី ជនជាតិ បែលហស្សិក នៅភ្នំពេញ
សូមជំរាបជូនសាធារណៈជនផងដែរថា ក្នុងចំណោម៧ករណីនេះ ៦ករណីគាត់ចំលងពីប្រទេសក្រៅ និង១ករណីប៉ះពាល់ផ្ទាល់ជាមួយជនជាតិជប៉ុន។
ប្រទេសកម្ពុជាយើងមិនទាន់រកឃើញភស្តុតាងបញ្ជាក់ថាមានការឆ្លងនៅក្នុងសហគមន៍នៅឡើយទេ ។
ទូទាំងប្រទេសយើងបានធ្វើតេស្តសរុបទាំងអស់ចំនួន ៩៧៥ករណី
ពត៌មានបន្ថែមសូមទាក់ទងលេខ ១១៥

 

---

រកឃើញ បុរសជនជាតិអង់គ្លេស អាយុ ៧៣ឆ្នាំ និង ស្រ្តីជនជាតិអង់គ្លេស អាយុ ៦៩ឆ្នាំ ជាភរិយា មានផ្ទុកមេរោគ **COVID-19** នៅខេត្តកំពង់ចាម



---

បច្ចុប្បន្នភាព ម៉ោង ៥ល្ងាច ថ្ងៃទី១១ មីនា ២០២០ :

ប្រទេសយើងបានរកឃើញករណីជំងឺCOVID-19 សរុបចំនួន៣ករណី
- ១ករណី ជនជាតិចិន ភេទប្រុស អាយុ៦០ឆ្នាំ ជាសះស្បើយ
- ១ករណី ជនជាតិខ្មែរ ភេទប្រុស អាយុ៣៨ឆ្នាំ កំពុងដាក់ព្យាបាលនៅមន្ទីរពេទ្យបង្អែកខេត្តសៀមរាប គាត់មានសុខភាពល្អ មិនមានរោគសញ្ញាអ្វីទេ តែគាត់បន្តវិជ្ជមាន COVID-19 ។ អ្នកប៉ះពាល់ទាំងអស់មិនទាន់រកឃើញវិជ្ជមាន COVID-19 ឡើយដែរ ។
- ១ករណី ជនជាតិអង់គ្លេស ភេទស្រី អាយុ៦៥ឆ្នាំ កំពុងដាក់ព្យាបាលនៅមន្ទីរពេទ្យបង្អែកខេត្តកំពុងចាម គាត់មានសុខភាពល្អ មិនមានរោគសញ្ញាអ្វីគួរឲ្យកត់សំគាល់ទេ
នេះជាករណីនាំចូលពីប្រទេសពីប្រទេស ។ អ្នកប៉ះពាល់ដូចជា ស្រ្តីអ្នកបកប្រែ អ្នកបើកម៉ូតូកង់៣ និងកូនគាត់ សុទ្ធតែអវិជ្ជមានCOVID-19 ។
អ្នកក្នុងកប៉ាល់ទាំងអស់បានយកវត្ថុវិភាគ ដាក់ឲ្យនៅដោយឡែក និងតាមដានសុខភាពចំនួន១៤ថ្ងៃ ។
ប្រទេសកម្ពុជាយើងមិនទាន់រកឃើញភស្តុតាងបញ្ជាក់ថាមានការឆ្លងនៅក្នុងសហគមន៍នៅឡើយទេ ។
ទូទាំងប្រទេសយើងបានធ្វើតេស្តសរុបទាំងអស់ចំនួន ៤៩៣ករណី
ពត៌មានបន្ថែមសូមទាក់ទងលេខ ១១៥

---

រកឃើញ ស្រ្តីជនជាតិអង់គ្លេសម្នាក់ទៀត ផ្ទុកមេរោគ **COVID-19** នៅខេត្តកំពង់ចាម



បច្ចុប្បន្នភាព ម៉ោង ៨:៣០នាទីយប់ ថ្ងៃទី១០ មីនា ២០២០ :
ប្រទេសយើងបានរកឃើញករណីជំងឺCOVID-19 សរុបចំនួន៣ករណី
- ១ករណី ជនជាតិចិន ភេទប្រុស អាយុ៦០ឆ្នាំ ជាសះស្បើយ
- ១ករណី ជនជាតិខ្មែរ ភេទប្រុស អាយុ៣៨ឆ្នាំ កំពុងដាក់ព្យាបាលនៅមន្ទីរពេទ្យបង្អែកខេត្តសៀមរាប គាត់មានសុខភាពល្អ មិនមានរោគសញ្ញាអ្វីទេ តែគាត់បន្តវិជ្ជមាន COVID-19
- ១ករណី ជនជាតិអង់គ្លេស ភេទស្រី អាយុ៦៥ឆ្នាំ កំពុងដាក់ព្យាបាលនៅមន្ទីរពេទ្យបង្អែកខេត្តកំពុងចាម គាត់មានសុខភាពល្អ
មិនមានរោគសញ្ញាអ្វីគួរឲ្យកត់សំគាល់ទេ ។ អ្នកប៉ះពាល់ទាំងអស់នឹងយកវត្ថុវិភាគ ដាក់ឲ្យនៅដោយឡែក និងតាមដានសុខភាពចំនួន១៤ថ្ងៃ ។
នេះជាករណីនាំចូលពីប្រទេសពីប្រទេសក្រៅ ។
ប្រទេសកម្ពុជាយើងមិនទាន់រកឃើញភស្តុតាងបញ្ជាក់ថាមានការឆ្លងនៅក្នុងសហគមន៍នៅឡើយទេ ។
ទូទាំងប្រទេសយើងបានធ្វើតេស្តសរុបទាំងអស់ចំនួន ៤៨២ករណី
ពត៌មានបន្ថែមសូមទាក់ទងលេខ ១១៥

---

បច្ចុប្បន្នភាព ម៉ោង ៥:៣០នាទីល្ងាច ថ្ងៃទី៩ មីនា ២០២០ :
ប្រទេសយើងបានរកឃើញករណីជំងឺCOVID-19 សរុបចំនួន២ករណី
- ១ករណី ជនជាតិចិន ភេទប្រុស អាយុ៦០ឆ្នាំ ជាសះស្បើយ
- ១ករណី ជនជាតិខ្មែរ ភេទប្រុស អាយុ៣៨ឆ្នាំ កំពុងដាក់ព្យាបាលនៅមន្ទីរពេទ្យបង្អែកខេត្តសៀមរាប គាត់មានសុខភាពល្អ មិនមានរោគសញ្ញាអ្វីទេ តែគាត់បន្តវិជ្ជមាន COVID-19
- អ្នកប៉ះពាល់ផ្ទាល់ និងប្រយោលជាមួយអ្នកជំងឺជនជាតិជប៉ុន និងជនជាតិខ្មែរ អវិជ្ជមានទាំងអស់ តែត្រូវបន្តតាមដានបង្គ្រប់១៤ថ្ងៃ
- សេចក្តីសន្និដ្ឋានរួម របស់មន្ត្រីជំនាញ អង្គការសុខភាពពិភពលោក មជ្ឈមណ្ឌលប្រយុទ្ធនឹងជំងឺឆ្លង សហរដ្ឋអាមេរិក វិទ្យាស្ថានប៉ាស្ទ័រកម្ពុជា
និងនាយកដ្ឋានប្រយុទ្ធនឹងជំងឺឆ្លងកម្ពុជា: មិនទាន់រកឃើញភស្តុតាង បញ្ជាក់ថាមានការឆ្លងនៅក្នុងសហគមន៍នៅឡើយទេ។
នៅទូទាំងប្រទេស យើងបានធ្វើតេស្តសរុបទាំងអស់ចំនួន ៤៦២ករណីហើយ។
ពត៌មានបន្ថែមសូមទាក់ទងលេខ ១១៥

---



រហូតដល់ម៉ោង ៨យប់ ថ្ងៃទី ៧ មីនា ២០២០ យើងបានរកឃើញករណីថ្មីមួយទៀត ដែលគាត់ជាជនជាតិខ្មែរ ភេទប្រុស អាយុ ៣៨ឆ្នាំ
ដែលគាត់បានប៉ះពាល់ផ្ទាល់ជាមួយអ្នកជំងឺជនជាតិជប៉ុនមានវិជ្ជមាន COVID-19
ហើយ៣នាក់ផ្សេងទៀតដែលប៉ះពាល់ផ្ទាល់ដែរមិនបានរកឃើញវិជ្ជមាន COVID-19 ទេ ។ ដូច្នេះយើងមាន២ករណីហើយ ក្នុងប្រទេសយើង
ដែលយើងរកឃើញករណីមុន ដែលគាត់ជាជនជាតិចិន ហើយគាត់បានព្យាបាលជាសះស្បើយដោយគ្រូពេទ្យនៅក្រុងព្រះសីហនុ
និងបានវិលត្រលប់ទៅប្រទេសចិនវិញ នៅថ្ងៃទី ១០ កុម្ភ: ២០២០ ។ រហូតពេលនេះ ប◌ុរសអាយុ៣៨ឆ្នាំ មានសុខភាពល្អ និងមិនមានរោគសញ្ញានោះទេ ។
ដោយឡែកអ្នកប៉ះពាល់ផ្ទាល់ ៤នាក់ ទៀត និង ៤០នាក់ប៉ះពាល់ប្រយោល ជាមួយអ្នកជំងឺជនជាតិជប៉ុន ដែលតំរូវឱ្យគាត់នៅដោយឡែកពីគេចំនួន ១៤ថ្ងៃ
និងតាមដានសុខភាពនោះ រហូតពេលនេះពួកគាត់ពុំទាន់មានរោគសញ្ញានៅឡើយទេ តែយើងក៏តំរូវយកវត្ថុវិភាគទាំងអស់មកពិនិត្យ ។
យើងនៅតែបន្តធ្វើការងារខាងលើនេះដោយសហការយ៉ាងជិតស្និទ្ធជាមួយអាជ្ញាធរដែនដី មន្ត្រីអង្គការសុខភាពពិភពលោក WHO មជ្ឈមណ្ឌលប្រយុទ្ធនឹងជំងឺឆ្លង
សហរដ្ឋអាមេរិក USCDC និងវិទ្យាស្ថានប៉ាស្ទ័រកម្ពុជា IPC ។
ពត៌មានបន្ថែមសូមទាក់ទងលេខ ១១៥

---

រហូតដល់ម៉ោង ៥ ល្ងាច ថ្ងៃទី ៦ មីនា ២០២០ យើងនៅមិនទាន់រកឃើញករណីថ្មីនៅឡើយទេ យើងនៅតែរក្សា ១ករណី ដដែល ដែលគាត់ជាជនជាតិចិន
ហើយគាត់ត្រូវបានព្យាបាលអោយ ជាសះស្បើយដោយគ្រូពេទ្យ នៅក្រុងព្រះសីហនុ និងបានវិលត្រលប់ទៅប្រទេសចិនវិញ នៅថ្ងៃទី ១០ កុម្ភ: ២០២០ ។
យើងបានធ្វើតេស្តកើនដល់ ៤២៥ ករណី តែមិនបានរកឃើញវិជ្ជមានមេរោគ COVID-19 នោះទេ ។ ដោយឡែកអ្នកប៉ះពាល់ផ្ទាល់ ៤នាក់ និង ៤០នាក់
ប៉ះពាល់ប្រយោល ជាមួយអ្នកជំងឺជនជាតិជប៉ុន ដែលតំរូវឱ្យគាត់នៅដោយឡែកពីគេចំនួន ១៤ថ្ងៃ និងតាមដានសុខភាពនោះ រហូតពេលនេះ
ពួកគាត់ពុំទាន់មានរោគសញ្ញានៅឡើយទេ ។ យើងនៅតែបន្តធ្វើការងារខាងលើនេះ ដោយសហការយ៉ាងជិតស្និទ្ធ ជាមួយអាជ្ញាធរដែនដី
មន្ត្រីអង្គការសុខភាពពិភពលោក WHO មជ្ឈមណ្ឌលប្រយុទ្ធនឹងជំងឺឆ្លងសហរដ្ឋអាមេរិក USCDC និងវិទ្យាស្ថានប៉ាស្ទ័រកម្ពុជា IPC ។
ពត៌មានបន្ថែមសូមទាក់ទងលេខ ១១៥

---

បន្ថែមមួយករណីថ្មីនេះ ធ្វើឲ្យកម្ពុជាបានរកឃើញអ្នកកើតជំងឺ Covid-19 ចំនួន៨ករណីហើយ ដោយក្នុងនោះមាន៖

ទី១៖ បុរសជនជាតិចិន មកពីទីក្រុងវូហាន (ជាសះស្បើយ)

ទី២៖ បុរសជនជាតិខ្មែរ វ័យ៣៨ឆ្នាំ នៅខេត្តសៀមរាប

ទី៣៖ ស្ត្រីជនជាតិអង់គ្លេស វ័យ៦៥ឆ្នាំ អ្នកដំណើរនាវា Viking Cruise Journey នៅខេត្តកំពង់ចាម

ទី៤៖ បុរសជនជាតិអង់គ្លេស វ័យ៧៣ឆ្នាំ អ្នកដំណើរនាវា Viking Cruise Journey នៅខេត្តកំពង់ចាម

ទី៥៖ ស្រីជនជាតិអង់គ្លេស វ័យ៦៩ឆ្នាំ អ្នកដំណើរនាវា Viking Cruise Journey នៅខេត្តកំពង់ចាម។

ទី៦៖ បុរសជនជាតិកាណាដា អាយុ៤៩ឆ្នាំ នៅរាជធានីភ្នំពេញ

ទី៧៖ បុរសជនជាតិប៊ែលហ្សិក អាយុ៣៣ឆ្នាំ នៅរាជធានីភ្នំពេញ

ទី៨៖ បុរសជនជាតិបារាំង អាយុ៣៥ឆ្នាំ នៅរាជធានីភ្នំពេញ៕

## សារអប់រំទាក់ទងនឹងកូវី ១៩

---

***Date: 23/March/2020***

ការកាត់បន្ថយហានិភ័យពីការឆ្លងកូវីត១៩ (COVID19) ដោយវិធីដ៏សាមញ្ញដូចខាងក្រោម៖

ពត៌មានបន្ថែមសូមទាក់ទងលេខ ១១៥

   

## សូមថ្លែងអំណរគុណ យ៉ាងជ្រាលជ្រៅជូនចំពោះ សប្បុរសជន ដែលបានឧបត្ថម្ភថវិកា ដល់មន្ត្រីទទួលបន្ទុក ទូរស័ព្ទទាន់ហេតុការណ៍ ១១៥ នឹងមន្ត្រីនាយកដ្ឋាន ប្រយុទ្ធនឹងជំងឺឆ្លង

***Date: 23/March/2020***

យើងខ្ញុំសូមថ្លែងអំណរគុណ យ៉ាងជ្រាលជ្រៅជូនចំពោះ សប្បុរសជន ដូចមានរាយនាមខាងក្រោម ដែលបានឧបត្ថម្ភថវិកា
ដល់មន្ត្រីទទួលបន្ទុកទូរស័ព្ទទាន់ហេតុការណ៍ ១១៥ (២៤ម៉ោង/៧ថ្ងៃ) និងមន្ត្រីនាយកដ្ឋានដើម្បីលើកទឹកចិត្ត និងរួមចំណែកក្នុងការប្រយុទ្ធ និងទប់ស្កាត់ជំងឺកូវីដ១៩
សូមប្រសិទ្ធពរបវរសួស្តីមហាប្រសើរ ជូនដល់លោកឧកញ៉ា លោកជំទាវ លោក លោកស្រី ទទួលបាននូវពុទ្ធពរទាំងបួនប្រការគឺ អាយុ វណ្ណៈ សុខៈ និងពលៈ កុំបីឃ្លៀងឃ្លាតឡើយ។
យើងខ្ញុំសូមយកឱកាសនេះ ថ្លែងអំណរគុណដល់រាជរដ្ឋាភិបាល ដែលបានឧបត្ថម្ភ និងលើកទឹកចិត្តដល់យើងខ្ញុំផងដែរ។

ថ្ងៃ ចន្ទ ១៥រោច ខែ ផល្គុន ឆ្នាំ កុរ ឯកស័ក ព.ស ២៥៦៣
រាជធានីភ្នំពេញ ថ្ងៃទី ២៣ ខែ មីនា ឆ្នាំ ២០២០

  

## នីតិវិធីដាក់ខ្លួន អោយនៅដាច់ដោយឡែក ក្នុងរយះពេល១៤ថ្ងៃ ដើម្បីបង្ការ និងទប់ស្កាត់ជំងឺកូវីត១៩ នៅតាមផ្ទះដាលក្ខណ:បុគ្គល

***Date: 22/March/2020***

សូមបងប្អូនដែលទើបធ្វើដំណើរ ត្រលប់ពីបរទេសទាំងអស់ សូមមេត្តាដាក់ខ្លួនឯង ឲ្យនៅដាច់ដោយឡែក ចំនួន១៤ថ្ងៃ និងតាមដានសុខភាព បើមានចេញរោគសញ្ញា សូមពិគ្រោះជំងឺជាមួយទូរស័ព្ទលេខ ១១៥ ។ សូមអានសេចក្តីណែនាំរបស់ក្រសួងសុខាភិបាល ។



## មេរោគកូរ៉ូណាវីរុសប្រភេទថ្មី ឆ្លងតាមរយ:ដំណក់ទឹកតូចៗ ដែលខ្ទាតចេញមកក្រៅ តាមរយ:ការក្អកឬកណ្តាស់

***Updated: 19/March/2020***

   

មេរោគកូរ៉ូណាវីរុសប្រភេទថ្មី ឆ្លងតាមរយ:ដំណក់ទឹកតូចៗ ដែលខ្ទាតចេញមកក្រៅតាមរយ:ក្អកឬកណ្តាស (មិនមែនហោះហើរក្នុងខ្យល់ទេ) ។ ត្រូវចងចាំថា ដំណក់ទឹកតូចៗអ្នកជំងឺដល់ទីណា មេរោគនឹងទៅដល់ទីនោះ ។ អ្នកវិទ្យាសាស្ត្ររកឃើញថា ចំងាយខ្ទាតចេញពីមុខមនុស្សយើងចំងាយបាន ៣ហ្វីត បើគិតពីរង្វាស់ម៉ែត្រគឺ ៩០សង់ទីម៉ែត្រ ។ ដូច្នេះបើយើងនៅឆ្ងាយពីអ្នកជំងឺលើសពី១ម៉ែត្រ យើងនឹងគេចផុតពីដំណក់ទឹកតូចៗទាំងនោះ ។
ពេលអ្នកជំងឺក្អកឬកណ្តាសម្តងៗ បណ្តាលឱ្យខ្ទាតទៅលើផ្ទៃផ្សេងៗ ដូចជាលើតុ លើជញ្ជាំង លើបង្កាន់ដៃ ។ ល។ និងដៃរបស់គាត់ក្រោយញ្ញើច្រមុះប្រលាក់សំបោរ ប៉ះដៃទ្វារប៉ះជញ្ជាំងប៉ះបង្កាន់ដៃ ដែលអ្នកជាប៉ះផ្ទៃទាំងនោះបណ្តាលឱ្យឆ្លងពេលយើងប៉ះមុខនិងច្រមុះ ។ អ្នកវិទ្យាសាស្ត្ររកឃើញថា ក្នុងមួយថ្ងៃមនុស្សយើងប៉ះមុខជាមធ្យម ៦០ដង ។ ហេតុដូច្នេះ តំរូវឱ្យអ្នកជំងឺត្រូវពាក់ម៉ាស់ដើម្បីកុំឱ្យខ្ទាតចេញមកក្រៅ នឹងទាំងអ្នកឈឺនិងអ្នកជាត្រូវតែឧស្សាហ៍លាងដៃជាមួយសាប៊ូ អាល់កុល ជេល ជាដើម ។ ចំពោះអ្នកជាពុំចាំបាច់ពាក់ម៉ាស់ទេ គឺយើងពាក់ម៉ាស់នៅពេលចាំបាច់ដូចជា កន្លែងប្រមូលផ្តុំ សួរសុខទុក្ខអ្នកជំងឺ និងក្រុមគ្រូពេទ្យ ហើយគ្រវាត់ម៉ាស់ក្នុងធុងសំរាមភ្លាមក្រោយប្រើប្រាស់ ។
ពត៌មានបន្ថែមសូមទាក់ទងលេខ ១១៥


- លេខ ១១៥ មានអ្នកទូរស័ព្ទចូលរហូតដល់ ជាង៩៣ម៉ឺននាក់ គិតចាប់ពីពេលរកឃើញកូវិត១៩ ករណីទី១មក
- A passenger on flight PG933 from Bangkok to Phnom Penh (9 MARCH 2020) has tested positive for COVID19
- របៀបដោះស្រាយ នៅពេលយើងមានបញ្ហាធុញថប់ តានតឹង ក្នុងកំឡុងពេលមានការរកឃើញ ករណីជំងឺកូវីត១៩ ជាបន្តបន្ទាប់ ក្នុងប្រទេសយើង
- ក្រសួងសុខាភិបាលកម្ពុជា ដាក់បំរាមផ្អាកមិនអោយជនបរទេស ដែលមកពីប្រទេស អ៊ីតាលី អាល្លឺម៉ង់ អេស្ប៉ាញ បារាំង និង អាមេរិក ចូលមកក្នុងប្រទេសកម្ពុជា

- Press Release
  - Avian Influenza
  - SARS
  - Severe Watery Diarrhea
  - Swine Influenza
  - Other Disease
  - MERS
- Bulletins
  - Year 9 (2012)
  - Year 8 (2011)
  - Year 7 (2010)
  - Year 6 (2009)
  - Monthly respiratory buttletin
    - Year 2014
    - Year 2015
    - Year 2016
    - Year 2017
- IEC material and documents
  - Posters
  - Booklets
  - Radio Spot
  - TV Spots
  - Leaflet
  - National Guideline, Policy, and Strategy
- Applied epidemiology training
  - Course detail
  - Team and advisory board
  - First cohort (2011)
  - Second cohort (2012)
  - Documents and forms
- Collaborative Projects with Hopital Service


## Latest Articles

- បច្ចុប្បន្នភាពនៃជំងឺកូវីដ-១៩ COVID-19 នៅប្រទេសកម្ពុជា
- សារអប់រំទាក់ទងនឹងកូវីដ ១៩
- COVID-19 Documents Management
- សូមថ្លែងអំណរគុណ យ៉ាងជ្រាលជ្រៅជូនចំពោះ សប្បុរសជន ដែលបានឧបត្ថម្ភថវិកា ដល់មន្ត្រីទទួលបន្ទុក ទូរស័ព្ទទាន់ហេតុការណ៍ ១១៥ និងមន្ត្រីនាយកដ្ឋានប្រយុទ្ធនឹងជំងឺឆ្លង
- នីតិវិធីដាក់ខ្លួន អោយនៅដាច់ដោយឡែក ក្នុងរយៈពេល១៤ថ្ងៃ ដើម្បីបង្ការ និងទប់ស្កាត់ជំងឺកូវីត១៩ នៅតាមផ្ទះជាលក្ខណៈបុគ្គល

## Login Form

User Name

Password

Remember Me

Log in

Forgot your username?
Forgot your password?

## Visitors Counter

| | |
|---|---|
| Today | 1233 |
| Yesterday | 2221 |
| This week | 1233 |
| This month | 59319 |
| Total | 991712 |

Powered by CoalaWeb

© 2020 CDC Department Website

Back to Top